ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

# សេចក្តីប្រកាសព័ត៌មាន

កាលពីរសៀលថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ ក្រសួងយុត្តិធម៌ បានរៀបចំកិច្ចប្រជុំស្តីពី **"ការជំរុញនីតិវិធីនៃសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសសម្អាតប្រាក់"** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានអនុគណៈកម្មការចំពោះកិច្ចទទួលបន្ទុកការងារប្រឆាំងការសម្អាតប្រាក់ **(អ.អ.ផ.)** និងដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម លោកជំទាវ** ជាប្រធានសាលាឧទ្ធរណ៍ភ្នំពេញ, ប្រធានសាលាឧទ្ធរណ៍តំបន់, អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ, អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់, ប្រធានសាលាដំបូងរាជធានី ខេត្ត និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ទូទាំងប្រទេស។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងជំរុញការអនុវត្តស្របតាមស្មារតីនៃលិខិតលេខ ០៧៦៨ កយ.រប/២២ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងយុត្តិធម៌ ស្តីពី **"ការជំរុញការពន្លឿនការអនុវត្តនីតិវិធីនៅក្នុងសំណុំរឿងសម្អាតប្រាក់នៅតាមសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់"** ដែលមានខ្លឹមសារស្នើដល់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដែលមានសំណុំរឿងសម្អាតប្រាក់ស្ថិតក្រោមចំណាត់ការរបស់ខ្លួន ពិសេស ចំពោះសំណុំរឿងនៃបទល្មើសក្នុងវិស័យដែលមានហានិភ័យខ្ពស់ពាក់ព័ន្ធនឹងការសម្អាតប្រាក់ ត្រូវបន្តខិតខំយកចិត្តទុកដាក់ប្រកបដោយស្មារតីម្ចាស់ការនិងការទទួលខុសត្រូវខ្ពស់ និងត្រូវផ្តល់អាទិភាពខ្ពស់លើការងារប្រឆាំងការសម្អាតប្រាក់ ដោយអនុវត្តឱ្យបានត្រឹមត្រូវ និងខ្ជាប់ខ្ជួន ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងនីតិវិធីប្រតិបត្តិស្តង់ដាប្រឆាំងការសម្អាតប្រាក់។

**ឯកឧត្តមរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ការបន្តចូលរួមចំណែកប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ លើការងារប្រឆាំងការសម្អាតប្រាក់ដែលជាកិច្ចការចាំបាច់ និងមានសារៈសំខាន់បំផុតសម្រាប់ប្រទេសជាតិនេះ គឺជាការបន្តចូលរួមចំណែកក្នុងកិច្ចខិតខំបន្តប្រឹងប្រែងសំដៅជួយឱ្យកម្ពុជាអាចត្រូវបានដកចេញពីបញ្ជីប្រផេះរបស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force - FATF) និងជួយពង្រឹងតម្លាភាព ជំនឿទុកចិត្ត និងភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ព្រមទាំងរួមចំណែកដល់ការប្រឆាំងហិរញ្ញប្បទានដល់អំពើភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលជាបញ្ហាសន្តិសុខរួមរបស់ពិភពលោក។ KR

ថ្ងៃពុធ ១កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២